# លទ្ធផលសង្ខេបនៃវេទិកាសាធារណៈថ្នាក់ជាតិ
# ស្តីពី
# “ការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការនៃការកសាងផែនការថវិកា និង ការតាមដានលើការចំណាយថវិកាសាធារណៈ ក្នុងបរិបទកូវីដ ១៩”

ថ្ងៃព្រហស្បតិ៍ ៧ រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ចាប់ពីម៉ោង ៨:០០ ដល់ម៉ោង ០៥:៣០ រសៀល
ទីកន្លែង: សណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា និងតាមអនឡាញ

ក្រុមការងារថវិកា ដែលសម្របសម្រួលដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានរៀបចំវេទិកាសាធារណៈស្តីពី ការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការនៃការកសាងផែនការថវិកា និងការតាមដានលើការចំណាយថវិកាសាធារណៈ ក្នុងបរិបទកូវីដ ១៩ ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ វេទិកានេះបានទទួលការអញ្ជើញចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗមានដូចជា៖ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលជាង ១០ រួមមានដូចជា អង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ ក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រសួងព័ត៌មាន អាជ្ញាធរមូលដ្ឋាន វិស័យឯកជន ទីភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងដៃគូរអភិវឌ្ឍន៍រួមមានដូចជា ប្រតិភូនៃសហភាព អឺរ៉ុប (EU) ស្ថានទូតស៊ុយអែត (Sweden) ប្រចាំកម្ពុជា អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ តំណាងសាកលវិទ្យាល័យ ស្ថាប័នសិក្សាស្រាវជ្រាវ និស្សិត យុវជន សហគមន៍ ជនជាតិដើមភាគតិច បងប្អូនប្រជាពលរដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន ដែលបានចូលរួមដោយផ្ទាល់ ៦០ (ស្រ្តី ១០នាក់) និងពីចម្ងាយតាមប្រព័ន្ធ Zoom ប្រមាណ ជាង ៣០០(បីរយនាក់) អ្នកទស្សនាតាមប្រព័ន្ធបណ្តាញសង្គមហ្វេសប៊ុក ចំនួន ៥ សរុបចំនួនប្រមាណ ៦០០០(ប្រាំមួយពាន់នាក់) និងមានមតិយោបល់ចូលរួមប្រមាណ ៣០០។

វេទិកានេះធ្វើឡើងក្នុងគោលបំណង៖

១) បង្កើនការយល់ដឹង និងលើកកម្ពស់ការចូលរួមរបស់សាធារណជន ទៅលើតម្លាភាព និងគណនេយ្យភាពថវិកា រួមទាំងដំណើរការនៃការរៀបចំផែនការថវិកា និងការអនុវត្តផែនការថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
២) ផ្តល់ឱកាសដល់អ្នកបង់ពន្ធរួមទាំងយុវជន សង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល បានជួបជជែកពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ និងអ្នកធ្វើគោលនយោបាយនានា សំដៅឆ្ពោះទៅបង្កើនការចូលរួមជាសាធារណៈនៅក្នុងវដ្តនៃដំណើរការរៀបចំផែនការថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
៣) ផ្តល់ឱកាសដល់អ្នកបង់ពន្ធរួមទាំងយុវជន សង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ផ្តល់នូវធាតុចូលជូនក្រសួងពាក់ព័ន្ធនិងអ្នកធ្វើគោលនយោបាយនានា សំដៅឆ្ពោះទៅធ្វើឲ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាថវិកាជាតិ ការបញ្ជ្រាបយេនឌ័រ គោលការណ៍បរិយាប័ន្ន និងជម្រើសផ្សេងទៀតដើម្បីលើកកម្ពស់ប្រសិទ្ធភាពផែនការថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

អ្នកចូលរួមវេទិកា ទាំងអស់បានបង្ហាញនូវអំណរសាទរដោយឃើញវត្តមានពីគ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ចូលរួមក្នុងការធ្វើបច្ចុប្បន្នភាព និងការពិភាក្សាប្រកបដោយស្មារតីយោគយល់ និងភាពជាដៃគូទាក់ទងនឹងប្រធានបទ។ យើងជឿជាក់យ៉ាងមុតមាំថា ប្រជាពលរដ្ឋកម្ពុជានឹងមានសំឡេង នៅក្នុងរបៀបនៃការចំណាយសាធារណៈក៏ដូចជានៅក្នុងការសម្រេចចិត្តនានា ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ ក្នុងឃុំ ស្រុក ក្រុង និងបរិស្ថានដែលពួកគេរស់នៅប្រចាំថ្ងៃ។

អង្គវេទិកានេះដំណើរការទៅដោយមានជាកិច្ចពិភាក្សាខ្លីៗទៅលើប្រធានបទសំខាន់ៗចំនួន៥រួមមាន៖

១- សារៈសំខាន់ និងកាតព្វកិច្ចរបស់ស្ថាប័នត្រួតពិនិត្យ

២- ការបន្សុីគ្នារវាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចគាំពារសង្គម

៣- ការរៀបចំថវិកាឆ្លើយតបទៅនឹងយេនឌ័រ

៤- ការវិនិយោគលើការអប់រំ និងកុមារ

៥- ការចូលរួមរបស់សាធារណជន ក្នុងដំណើរការកសាងផែនការរៀបចំថវិកា និងការត្រួតពិនិត្យ តាមដានការអនុវត្តផែនការថវិកានៅថ្នាក់ក្រោមជាតិ

ក្នុងប្រធានបទនីមួយៗ យើងបានពិភាក្សាគ្នាលើបីចំនុចធំដូចជា៖

១. **ចំណុចវិជ្ជមាន**នៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមក

២. **បញ្ហាប្រឈម**មួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមក

៣. **សំណូមពរ និងអនុសាសន៍**លើកទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនានា

**ជាលទ្ធផល យើងទាំងអស់គ្នាសូមសម្តែងនូវអំណរសាទរចំពោះចំណុចជាវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមកពាក់ព័ន្ធទៅនឹងការចូលរួមរបស់ពលរដ្ឋ ក្នុងដំណើរការរៀបចំថវិកានិងការត្រួតពិនិត្យតាមដានដែល មានចំនួនប្រមាណ៖ ៣៥ ចំណុចវិជ្ជមាន និងវឌ្ឍនភាព។ បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះទៅដល់គុណភាពនៃការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាដ៏គួរឱ្យកត់សម្គាល់ ដែលបានលើកឡើងក្នុងកិច្ចពិភាក្សានៃវេទិការួមមាន ៣៦ ចំណុច និងអនុសាសន៍ចំនួន ៤៥ចំណុច។**

ខាងក្រោមនេះគឺជាលទ្ធផលសង្ខេបនៃកិច្ចពិភាក្សា៖

**១.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមករបស់ស្ថាប័នត្រួតពិនិត្យថវិកា (៧ចំណុច)៖**

១.១.១ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយន្តការច្បាស់លាស់ក្នុងការរៀបចំថវិកាជាតិដោយមានស្ថាប័នទទួលខុសត្រូវច្បាស់លាស់មានដូចជាក្រសួងសាមី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សភា រដ្ឋសភា អាជ្ញាធរសវនកម្មជាតិ និងពលរដ្ឋ ព្រមទាំងជានាបាននូវតម្លាភាព និងលើកកម្ពស់ឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

១.១.២ រាជរដ្ឋាភិបាលបានបើកចំហរឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍន៍ដូចជាសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត ដើម្បីលើកកម្ពស់ឱ្យមានតម្លាភាពនិងគណនេយ្យភាព នៅក្នុងដំណើរគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេសកម្ពុជា។

១.១.៣ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ៥ឆ្នាំ សម្រាប់ឱ្យអង្គភាពប្រឆាំងអំពើពុករលួយអនុវត្ត ដែលផែនការយុទ្ធសាស្ត្រនេះមានលក្ខណៈប្រកបដោយបរិយាបន្នដោយផ្អែកលើបទដ្ឋានអន្តរជាតិ ដូចជាក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍សហប្រជាជាតិ (SDGs)ជាដើម។ ក្នុងនោះផងដែរ អង្គភាពប្រឆាំងអំពើពុករលួយតែងតែបានចូលរួមក្នុងការចូលរួមត្រួតពិនិត្យតាមដានការអនុវត្តរបស់ស្ថាប័នផ្សេងៗ។

១.១.៤ តាមរយៈរបាយការណ៍**ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា** បានបង្ហាញថារដ្ឋាភិបាលកម្ពុជាមានលក្ខណៈល្អប្រសើរជាងមុនក្នុងការចែករំលែកឯកសារទាក់ទងនិងថវិកានៅលើគេហទំព័រ។

១.១.៥ គណៈកម្មការទី១០នៃរដ្ឋសភា បានចូលរួមក្នុងការពិនិត្យ ក្នុងការរៀបចំ និងត្រួតពិនិត្យលើក្រសួងស្ថាប័ននេះជាចំណុចមួយដែលមានលក្ខណៈល្អប្រសើរ។

១.១.៦ មានការចែករំលែក និងសហប្រតិបត្តិការល្អនាពេលកន្លងមករវាងគណៈកម្មការទី១០នៃរដ្ឋសភា និងអង្គភាពប្រឆាំងអំពើពុករលួយ។

១.១.៧ រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់អភិបាលកិច្ចដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដែលមានជាតុសំខាន់ៗ មានដូចជាការចូលរួម គណនេយ្យភាពនៃអ្នកពាក់ព័ន្ធ តម្លាភាព និងជាតុសំខាន់ផ្សេងៗទៀតនៃអភិបាលកិច្ច។

**១.២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមករបស់ស្ថាប័នត្រួតពិនិត្យថវិកា(៦ចំណុច)៖**

១.២.១ អង្គនីតិបញ្ញត្តិមិនទាន់បានលើកកម្ពស់និងដាក់បញ្ចូលការចូលរួមរបស់អ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយក្នុងច្បាប់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឡើយ។

១.២.២ តាមរបាយការណ៍ការអង្កេតលើការបើកចំហរព័ត៌មានថវិកាកម្ពុជាមានការកើនឡើងបន្តិចមែន តែទោះបីជាយ៉ាងណាការលើកកម្ពស់នៃការចូលរួមពីសាធារណៈជននៅមានកម្រិតនៅឡើយ។ ម្យ៉ាងវិញទៀតតម្លាភាពថវិកា និងការត្រួតពិនិត្យថវិកាក៏នៅតែជាបញ្ហាប្រឈមនៅឡើយប្រសិនបើយើងប្រៀបធៀបជាមួយនិងបណ្ដាប្រទេសក្នុងតំបន់។

១.២.៣ មានការចែករំលែកព័ត៌មានខ្លះ តែការចែករំលែកព័ត៌មាន និងគុណភាពនៃព័ត៌មានថវិកាដែលផ្តល់ដោយរដ្ឋសភានៅមានកម្រិតសម្រាប់សាធារណៈជនទូទៅនៅឡើយជាពិសេសគឺសម្រាប់ស្ត្រី ជនពិការ និងជនជាតិដើមភាគតិច។តាមច្បាប់រដ្ឋធម្មនុញ្ញមាត្រា៣៥ បានចែងថាការចែករំលែកព័ត៌មាជាកាតព្វកិច្ចរបស់ រដ្ឋសភា។

១.២.៤ រដ្ឋសភាមិនទាន់មានយន្តការច្បាស់លាស់ក្នុងការបង្កើតគណៈកម្មការក្នុងការតាមដានការរៀបចំ និងការអនុវត្តថវិកា និងការឆ្លើយតបណាមួយពីរដ្ឋសភាជាផ្លូវការនៅឡើយនៅពេលដែលមានសំណួរដែលលើកឡើងដោយពលរដ្ឋ។

១.២.៥ ពុំទាន់មានយន្តការសាកល្បងណាមួយដើម្បីលើកកម្ពស់ឱ្យមានការចូលរួមពីសាធារណៈជនទូទៅក្នុងអំឡុងពេលបង្កើតថវិកា។

១.២.៦ ពុំទាន់មានវេទិកា ឬយន្តការជាប្រចាំសម្រាប់សាធារណៈជន ដើម្បីចូលរួមចំណែកក្នុងការ ត្រួតពិនិត្យការអនុវត្តថវិកាដែលបានអនុម័ត ដែលបើកចំហសម្រាប់ ប្រជាពលរដ្ឋដែលមានបំណងចូលរួម។

## ១.៣. សំណូមពរ និងអនុសាសន៍លើទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនៃការត្រួតពិនិត្យថវិកា(១៤ចំណុច)៖

១.៣.១ ស្នើឱ្យរដ្ឋសភានិងរាជរដ្ឋាភិបាលចាប់ផ្តើម ធ្វើការកែទម្រង់ដោយធ្វើឱ្យមានក្របខណ្ឌច្បាប់និងគោលនយោបាយដែលលើកកម្ពស់ការចូលរួមពីសាធារណជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យបានជាក់លាក់តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ដោយដាក់បញ្ចូលនូវមាត្រាដែលចែងអំពីការចូលរួមរបស់សាធារណជន សង្គមស៊ីវិល ចាប់តាំងពីដំណាក់កាលរៀបចំផែនការថវិកាកម្រិតក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីបើកឱកាសទទួលយកនូវធាតុចូល។

១.៣.២ ស្នើឱ្យក្រសួងសេដ្ឋកិច្ច សភា រដ្ឋសភា អាជ្ញាធរសវនកម្មជាតិ ជំរុញនិងលើកកម្ពស់បន្ថែមទៀតក្នុងការបង្កើនពិន្ទុទាក់ទងនិង ការអង្កេតលើការបើកចំហរព័ត៌មានថវិកាដែលក្នុងនោះកម្ពុជាគួរតែ បញ្ចេញឯកសារគន្លឹះទាំង៨ ដល់សាធារណៈជនតាមកាលកំណត់។ សំណើថវិកាចេញពីទីស្តីការគណៈរដ្ឋមន្ត្រីទៅរដ្ឋសភា គួរតែផ្សព្វផ្សាយជាមុនសិន។

១.៣.៣ ស្នើឱ្យធ្វើការបង្កើនចំណេះដឹងដល់ពលរដ្ឋបន្ថែមទៀតស្តីពីថវិកាជាតិដោយសហការជាមួយអង្គការសង្គមស៊ីវិល និងរៀបចំថវិកាសម្រាប់ប្រជាពលរដ្ឋ ជាពិសេសគឺយន្តការក្នុងការចូលរួមរបស់ប្រជាពលរដ្ឋទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១.៣.៤ ស្នើសម្រួលនិតិវិធីនៃការចូលរួមរបស់ពលរដ្ឋ ក្នុងការចូលរួមក្នុងដំណើរការរៀបចំថវិកា និងចូលរួមក្នុងដំណើរការតាមដានក្នុងការចំណាយរបស់ស្ថាប័នអនុវត្តថវិកាផ្សេងៗ។

១.៣.៥ ស្នើលើកកម្ពស់ឱ្យមានយន្តការ និងបរិយាកាសអំណោយផលដល់ប្រជាពលរដ្ឋ ក្នុងការទទួលបានទិន្នន័យសម្រាប់សាធារណៈជនទូទៅទាក់ទងនិងព័ត៌មានថវិកាជាតិ និងរបាយការណ៍សវនកម្មជាតិ។

១.៣.៦ ស្នើឱ្យស្ថាប័ននីតិប្បញ្ញត្តិ ពិភាក្សាអំពីគោលនយោបាយថវិកា និងផ្តល់អនុសាសន៍សម្រាប់កែសម្រួលថវិកាមុនពេលសំណើថវិកាត្រូវបានអនុម័ត។

១.៣.៧ ស្នើឱ្យគណៈកម្មាធិការនីតិប្បញ្ញត្តិពិនិត្យមើលសំណើថវិការបស់ក្រសួងពាក់ព័ន្ធហើយបោះពុម្ពផ្សាយរបាយការណ៍ជាមួយនឹងការវិភាគរបស់ខ្លួនជូនសាធារណៈជនតាមរយៈគេហទព័រឬប្រព័ន្ធអ៊ីនធឺណិត។

១.៣.៨ ស្នើឱ្យមានការលើកទឹកចិត្តក្នុងការបង្កើតឱ្យមានការចូលរួមតាមបែបឌីជីថល ជាពិសេសនៅកម្រិតថ្នាក់ក្រោមជាតិ។

១.៣.៩ ស្នើឱ្យក្រសួងសេដ្ឋកិច្ចធ្វើសេចក្តីរាយការណ៍លើការចំណាយថវិកាជាប្រចាំខែតារយៈគេហទំព័ររបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១.៣.១០ ស្នើឱ្យមានការចែករំលែកព័ត៌មាន និងគុណភាពនៃព័ត៌មាន ដល់ប្រជាពលរដ្ឋ ជាពិសេស ដល់ស្ត្រី និងប្រជាពលរដ្ឋដែលជាជនជាតិដើមភាគតិច។ ឯកសារទាក់ទងនិងច្បាប់ថវិកាគួរសម្រាយដើម្បីឱ្យមានលក្ខណៈ ងាយយល់ដែលប្រជាពលរដ្ឋទូទៅអាចអាន និងយល់បាន។ ព័ត៌មានសំខាន់ៗគួរតែចែករំលែកដល់ពលរដ្ឋដូចជាព័ត៌មានទាក់ទង និងបំណុល និងចំណូលពន្ធ។

១.៣.១១ ស្នើឱ្យសភាធ្វើការតាមដាននៅតាមមូលដ្ឋាន តាមក្រសួង និងធ្វើការសាកសួរនិងផ្សាយផ្ទាល់តាមប្រព័ន្ធផ្សព្វផ្សាយ និងគួរតែមានយន្តការប្រឹក្សាយោបល់ជាមួយប្រជាពលរដ្ឋ មុនពេលពិនិត្យដំដែកនិងកែសម្រួលលើសេចក្តីព្រាងថវិកាជាតិ។

១.៣.១២ ស្នើឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្កើតយន្តការសាកល្បងដើម្បីលើកកម្ពស់ឱ្យមានការចូលរួមពីសាធារណៈជនក្នុងអំឡុងពេលបង្កើតថវិកា។

១.៣.១៣ ស្នើឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្កើតវេទិកា ឬយន្តការជាប្រចាំសម្រាប់សាធារណៈជនដើម្បីចូលរួមចំណែកក្នុងការត្រួតពិនិត្យការអនុវត្តថវិកាដែលបានអនុម័តដែលបើកចំហសម្រាប់ប្រជាពលរដ្ឋដែលមានបំណងចូលរួម។

១.៣.១៤ ស្នើឱ្យរដ្ឋសភាកម្ពុជា អនុញ្ញាតឱ្យប្រជាពលរដ្ឋ ឬអង្គការសង្គមស៊ីវិលណាមួយ ផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការរបស់ខ្លួនលើសំណើថវិកា មុនពេលថវិកាត្រូវបានអនុម័ត។

**២.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមកនៃការបន្សុីគ្នារវាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចគាំពារសង្គម(១១ចំណុច)៖**

២.១.១ ក្នុងបរិបទកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជាបានគ្រោងវិភាជថវិកា១១០០ លានដុល្លាដើម្បីឆ្លើយតបនិងការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ ។

២.១.២ រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការក្នុងការគាំទ្រដល់កម្មករនិយោជិក ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ១៩។

២.១.៣ ក្រសួងការងារបានដាក់ចេញនូវសេចក្តីណែនាំ-លេខ៤៥-២០-ស្តីពីការព្យួរកិច្ចសន្យាការងារ-និងការផ្អាកបង់ភាគទាន-ប-ស-ស-សម្រាប់រោងចក្រ-សហគ្រាស-និងគ្រឹះស្ថានក្នុងវិស័យកាត់ដេរ-និងទេសចរណ៍-ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩។ កម្មករដែលក្រុមហ៊ុនដាក់ពាក្យព្យួរ នោះកម្មករនៅតែបន្តបានសេវាព្យាបាលថែនិងទាំដដែល។

២.១.៤ បេឡាជាតិ សន្តិសុខសង្គម (ប.ស.ស) កន្លងមកបានអនុវត្តគម្រោង២ គឺហានិភ័យការងារ និងការថែទាំសុខភាព។ ផ្នែកសោធន៍គ្រោងនឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០២២។

២.១.៥ កម្មករនិយោជិកធ្វើការក្រៅប្រព័ន្ធដែលនិយោជកបានចុះបញ្ជីជាមួយ ប.ស.ស នៅតែទទួលបានការថែទាំសុខភាពនិងថវិកានៅពេលសម្រាលកូន។

២.១.៦ សហគ្រាសខ្នាតតូចខ្នាតមធ្យម (SME) បានធ្វើតាមគោលការណ៍ដែលដាក់ចេញរបស់រាជរដ្ឋាភិបាល តាមលទ្ធភាពដែលអាចធ្វើទៅបានដោយបានគិតគូរដល់និយោជិករបស់ខ្លួនដូចជាចែកស្បៀង និងការគាំទ្រផ្សេងៗ របស់ខ្លួនក្នុងអំឡុងពេលបិទខ្ទប់។

២.១.៧ មិនទាន់មានក្រុមហ៊ុនដែលកាត់ប្រាក់ខែពីបុគ្គលិកទាំងស្រុងក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ ១៩ ។

២.១.៨ អង្គការសង្គមស៊ីវិល បានធ្វើការសិក្សាលើកម្មករដែលធ្វើការក្រៅប្រព័ន្ធដោយការចងក្រង និងសិក្សាពីផលប៉ះពាល់ក្នុងបរិបទកូវីដ១៩។

២.១.៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំនូវអនុគណៈកម្មការនៃផ្នែកជំនួយផ្នែកសង្គមដែលដើរតួនាទីក្នុងការត្រួតពិនិត្យលើផ្នែកជំនួយសង្គម។

២.១.១០ តាមឃុំសង្កាត់នីមួយៗបានដាក់ប្រព័ន្ធដោយប្រើប្រាស់(Taplet និង Hotline) ដើម្បីគ្រប់គ្រងទិន្នន័យទាក់ទងនិងជំនួយសង្គម ។

២.១.១១ រាជរដ្ឋាភិបាលបានផ្តល់សាច់ប្រាក់ដល់អ្នកប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ១៩ ប្រមាណ ៤៧០លានដុល្លា គិតត្រឹម ២៤ តុលា ឆ្នាំ ២០២១។

**២.២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមកនៃការបន្សុីគ្នារវាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចគាំពារសង្គម(៩ចំណុច)៖**

២.២.១ សហជីពមានការពិបាកក្នុងការស្វែងរកព័ត៌មានរបស់ក្រុមហ៊ុនស្ដីពីលំហូរសាច់ប្រាក់ និងផលចំណេញប្រចាំឆ្នាំ របស់ក្រុមហ៊ុនដែលកំពុងវិនិយោគនៅក្នុងប្រទេសកម្ពុជា។

២.២.២ ម្ចាស់ក្រុមហ៊ុនអាជីវកម្មខ្លះមានបញ្ហាហិរញ្ញវត្ថុនិងទីផ្សារដោយត្រូវចំណាយលើថ្លៃប្រាក់ខែកម្មករ និងថ្លៃការិយាល័យដែលក្រុមហ៊ុនខ្លះបង្ខំចិត្តក្នុងការកាត់បន្ថយបុគ្គលិក និងប្រាក់ខែ។

២.២.៣ ការគាំទ្រសម្រាប់វិស័យក្រៅប្រព័ន្ធនៅមានកម្រិតនៅឡើយដែលធ្វើឱ្យពួកគេជួបការលំបាកជាច្រើនទាក់ទងនិងការចិញ្ចឹមជីវិត។

២.២.៤ ការមិនទទួលបានជំនួយគ្រប់គ្រាន់ពីរដ្ឋាភិបាលៈ មានការផ្ដល់ថវិកាដល់កម្មករដែលរងផលប៉ះពាល់ការងារដោយសារតែការរាតត្បាតនៃជំងឺកូវីដ១៩ តែទោះបីជាយ៉ាងណាក៏ដោយចំនួននេះនៅតិចតួចនៅឡើយដោយសារតែពួកគេភាគច្រើនជំពាក់បំណុលធនាគារ និងត្រូវការថវិកាដើម្បីសង។ គោលនយោបាយមិនអាចយកមកអនុវត្តបាននៅមូលដ្ឋាន ជាក់ស្ដែងសេចក្ដីណែនាំ លេខ 142/20

២.២.៥ សេវាកម្មសុខាភិបាលសាធារណៈក្នុងបរិបទកូវីដ១៩ នៅមានកម្រិតនៅឡើយធ្វើឱ្យប្រជាពលរដ្ឋមានការលំបាកក្នុងការទទួលបានសេវាព្យាបាល។

២.២.៦ ពលរដ្ឋជាច្រើនដែលស្ថិតនៅក្នុងស្ថានភាពក្រីក្រកាន់តែរងគ្រោះជាងមុន ដោយឡែកប្រជាជនមួយចំនួនទៀតដែលពីមុនមិនស្ថិតនៅក្នុងភាពងាយរងគ្រោះមដល់ពេលនេះក៏បានធ្លាក់ខ្លួនក្នុងភាពក្រីក្រដោយសាតែការបន្តរីករាលដាលនៃជំងឺកូវីដ១៩ដែលកំពុងអូសបន្លាយ។

២.២.៧ បញ្ហាសុខភាពផ្លូវចិត្តក៏ជាបញ្ហាមួយផងដែរសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ១៩ផងដែរ។

២.២.៨ ការយល់លើកិច្ចគាំពារសង្គមនៅមានកម្រិតនៅឡើយនៅក្នុងបរិបទនៃប្រទេសកម្ពុជា។

២.២.៩ ការងារសមរម្យមិនទាន់មានលក្ខណៈស្តង់ដារដូចជាខ្វះសេរីភាពសហជីព សុខភាពសុវត្ថិភាព និងការទទួល កិច្ចគាំពារសង្គម។ កម្មករមិនមានសិទ្ធិក្នុងការដាក់លក្ខខ័ណ្ឌក្នុងការជជែកជាមួយនិយោជក

**២.៣. សំណូមពរ និងអនុសាសន៍លើទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនៃការបន្សីុគ្នារវាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចគាំពារសង្គម(៧)៖**

២.៣.១ ស្នើឱ្យរដ្ឋបាលភិបាលផ្ដល់ប័ណ្ណ ប.ស.សដល់អ្នកធ្វើការក្រៅប្រព័ន្ធផងដែរ។

២.៣.២ ស្នើឱ្យរដ្ឋាភិបាលផ្ដល់វគ្គបណ្ដុះបណ្ដាលអាជីវកម្ម និង គម្រោងខ្នាតតូចដល់ប្រជាពលរដ្ឋដែលប៉ះពាល់ពីរាតត្បាតនៃជំងឺកូវីដ១៩ ជាពិសេសអ្នកធ្វើការក្រៅប្រព័ន្ធ។

២.៣.៣ រដ្ឋាភិបាលគួរឈប់យកផាសុីផ្សារក្នុងអំឡុងពេលនៃការរីករាតត្បាតនៃជំងឺកូវីដ១៩ ខណៈដែលប្រជាពលរដ្ឋកំពុងតែជួបបញ្ហា។

២.៣.៤ ស្នើឱ្យជំរុញឱ្យមានភាពប្រក្រតីកម្មនៃសេដ្ឋកិច្ចឡើងវិញ ជាពិសេសអ្នកធ្វើការក្រៅប្រព័ន្ធ។

២.៣.៥ ស្នើឱ្យរដ្ឋាភិបាលជំរុញ និងពន្លឿនក្នុងការផ្ដល់ប្រាក់សោធននិវត្តន៍ដល់វិស័យឯកជន និងអង្គការសង្គមសុីវិល ។

២.៣.៦ ស្នើឱ្យមានយន្តការបណ្ដុះបណ្ដាលបន្ថែមទៀតទាក់ទងនិងកិច្ចគាំពារសង្គមដល់អ្នកពាក់ព័ន្ធដោយសាកិច្ចការនេះជាការងារថ្មីនៅក្នុងបរិបទនៃប្រទេសកម្ពុជា។

២.៣.៧ ស្នើឱ្យរដ្ឋាភិបាលជំរុញនិងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការបង្កើតធុរកិច្ចបរិយាប័ន្ន ព្រមទាំងផ្ដល់រង្វាន់លើកទឹកចិត្តដល់ក្រុមហ៊ុនដែលបានអនុវត្តនូវគំរូធុរកិច្ចនេះ។

**៣.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមកនៃថវិកាឆ្លើយតបទៅនឹងយេនឌ័រ (៧ចំណុច)៖**

៣.១.១ ក្រសួងកិច្ចការនារីបានរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈក្នុងការលើកម្ពស់ សមភាពយេនឌ័រ និងបង្កើតភាពអង់អាចដល់ស្ត្រី ដែលមាន យុទ្ធសាស្ត្រ២ ផ្ដោត លើការជំរុញ និងសម្របសម្រួលការបញ្ជ្រាបយេនឌ័រ

នៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីជាតិ រួមទាំងការងារកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិសហមជ្ឈការ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការរៀបចំសកម្មភាពជាក់លាក់ ដូចជា៖

- រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ស្តីពីការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រដល់ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីជំនាញថវិកា។
- ចងក្រងមេរៀនបទពិសោធន៍ នានា ក្នុងការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ។

៣.១.២ តាមរយៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាល់ការរៀបចំថវិកាតាមកម្មវិធីរបស់ក្រសួង ស្ថាប័នត្រូវបន្សុីទៅនឹងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ដូចនេះក្រុមការងារបញ្ជ្រាបយេនឌ័រតាមវិស័យ នៅតាមក្រសួង ស្ថាប័ន បាន និងកំពុងរៀបចំផែនថវិកាឱ្យការឆ្លើយតបនឹងយេនឌ័រតាមវិស័យរបស់ខ្លួន។

៣.១.៣ រដ្ឋបាលឃុំសង្កាត់បានអញ្ជើញ ស្ត្រីឱ្យចូលរួម និងបញ្ចេញ មតិយោបល់ក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំសង្កាត់។

៣.១.៤ ថវិកាឆ្លើយតបនិងតម្រូវការយេនឌ័រមានការកើនឡើងជារៀងរាល់ឆ្នាំ លើកលែងតែរយៈពេលពីឆ្នាំចុងក្រោយនេះ។

៣.១.៥ មានការបើកចំហរខ្លះឱ្យមានដំណើរការចូលរួមរបស់យុវជននៅ កម្រិតឃុំសង្កាត់ក្នុងបណ្តាឃុំសង្កាត់មួយចំនួននៅក្នុងប្រទេសកម្ពុជា។

៣.១.៦ ក្រសួងកិច្ចការនារីមានក្រុមការងារក្នុងការដោះស្រាយនិងមើលពីតម្រូវការ នៅតាមស្ថាប័នដើម្បីរៀបចំផែនការឆ្លើយតបទៅនិងតម្រូវការ។

៣.១.៧ មាន គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) នៅតាមឃុំសង្កាត់នីមួយៗ។

## ៣.២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមកនៃថវិកាឆ្លើយតបទៅនឹងយេនឌ័រ (៩ចំណុច)៖

៣.២.១ ការចូលរួមរបស់សាធារណៈជនក្នុងការរៀបចំថវិកានៅមានកម្រិតនៅឡើយជាពិសេស ស្ត្រី ជនពិការ កុមារ និងជនជាតិដើមភាគតិច។

៣.២.២ ការវិភាជថវិកាឆ្លើយតបនិងតម្រូវការយេនឌ័រនៅតិចតួចនៅឡើយ ដោយសារសមត្ថភាពរបស់ក្រុមប្រឹក្សា ឃុំនៅមានកម្រិតនៅឡើយក្នុងការផ្សារភ្ជាប់ថវិកាជាមួយនិងយេនឌ័រ។ នៅថ្នាក់ជាតិក៏នៅមានកម្រិតដែរ។

៣.២.៣ យើងមានយន្តការលើកកម្ពស់ឱ្យមានការចូលរួមរបស់ស្ត្រីតែទោះបីជាយ៉ាងណាក៏ដោយការចូលរួមក្នុងការកសាងផែនការវិនិយោគឃុំសង្កាត់នៅមានកម្រិត ពីសំណាក់ ស្ត្រី កុមារ ចាស់ជរា ជនពិការ និងជនជាតិដើមភាគតិច។

៣.២.៤ លំហូថវិកាពីថ្នាក់ជាតិដើម្បីមកអនុវត្តថ្នាក់ក្រោមជាតិមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ថវិកាមិនទាន់មានសមភាព និងយុត្តិធម៌នៅឡើយ។

៣.២.៥ ខ្វះប្រព័ន្ធថវិកាដែលកំណត់ជាលេខគណនីជាក់លាក់សម្រាប់ថវិកាឆ្លើយតបនិងយេនឌ័រ។ កន្លងមកយើងមានត្រឹមតែទិន្នន័យបែងចែកតាមភេទ។យើងខ្វះនូវទិន្នន័យដែលជាអំណាចក្នុងការសម្រេចចិត្ត។

៣.២.៦ មិនមានទិន្នន័យច្បាស់លាស់ទាក់ទងនិងការខ្វះខាតថវិកាយេនឌ័រច្បាស់លាស់ ដើម្បីធ្វើការសម្រេចចិត្តរៀបចំយន្តការបន្តរ។

៣.២.៧ មិនមានសូចនាករច្បាស់លាស់ឬស្តង់ដាទាក់ទងនិងយេនឌ័រនៅតាមក្រសួងស្ថាប័ន។

៣.២.៨ ការយល់ដឹងទៅលើថវិកាឆ្លើយតបនិងយេនឌ័រចំពោះអ្នកពាក់ព័ន្ធនៅមានកម្រិតនៅឡើយដោយភាគច្រើនគេយល់ថវិកាឆ្លើយតបនិងយេនឌ័រគឺផ្តោតតែលើស្ត្រី។

៣.២.៩ អ្នកពាក់ព័ន្ធនៅមានការយល់ដឹងអំពីការវាយតម្លៃអំពីតម្រូវការយេនឌ័រ ឬការវិភាគយេនឌ័រតិចតួចនៅឡើយ។

**៣.៣. សំណូមពរ និងអនុសាសន៍លើទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនៃថវិកាឆ្លើយតបទៅនឹងយេនឌ័រ(៨ចំណុច)៖**

៣.៣.១ ស្នើឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិលើកកម្ពស់ឱ្យមានការចូលរួមបន្ថែមទៀតជាពិសេស ការចូលរួមពីស្ត្រី កុមារ ជនពិការ ចាស់ជរា ចូលរួមកសាងផែនការវិនិយោគឃុំសង្កាត់

៣.៣.២ ស្នើឱ្យមានការវិភាជថវិកាបន្ថែមពីថ្នាក់ជាតិបន្ថែមទៀតដើម្បីឆ្លើយតបនិងតម្រូវការយេនឌ័រ។

៣.៣.៣ ស្នើឱ្យមានការបណ្តុះបណ្តាលបន្ថែមទៀតទាក់ទងនិងការវិភាគយេនឌ័រដល់សាធារណៈជនទូទៅ និងអ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៣.៣.៤ ស្នើឱ្យមានការផ្សព្វផ្សាយពីសេវាកម្ម ដែលពលរដ្ឋទទួលបាន និងផ្សព្វផ្សាយពីវិធីសាស្ត្រដែលពលរដ្ឋអាចចូលរួមក្នុងដំណើរការរៀបចំថវិកាបាន។

៣.៣.៥ ស្នើដល់អាជ្ញាធរមូលដ្ឋាន លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងការចូលរួមធ្វើផែនការវិនិយោគឃុំសង្កាត់។

៣.៣.៦ ស្នើឱ្យរដ្ឋាភិបាលពិចារណាក្នុងការប្រើប្រាស់ឧបករណ៍មួយចំនួនដូចជាក្នុងការវាស់វែងយេនឌ័រ សវនកម្មយេនឌ័រ ការវិភាគលើចំណាយសាធារណៈដោយយកទស្សនទានសមភាពយេនឌ័រ និងការវិភាគលើអត្ថប្រយោជន៍ ដោយផ្តោតលើការបែងចែកធនធាន។

៣.៣.៧. ថវិកាយេនឌ័រគួចាប់ផ្តើមជាមួយការវាយតម្លៃ អំពីតម្រូវការយេនឌ័រ ផ្តោតលើការទទួលខុសត្រូវរបស់បុរស និងស្ត្រី និងតម្រូវការ។

៣.៣.៨. កសាងសមត្ថភាព ស្តីពីការវិភាគយេនឌ័រ នៅក្នុងវិស័យ តាមរយៈ ការប្រមូលទិន្នន័យ ដែលមានការបែងចែកតាមភេទ ស្ថានភាព អាយុ ការអប់រំ ភាពងាយរងគ្រោះ និងសក្តានុពលនានាតាមវិស័យ។

**៤.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមកនៃការវិនិយោគលើការអប់រំ និងកុមារ (៥ចំណុច)៖**

៤.១.១ ក្រសួងអប់រំយុវជននិងកីឡាបានប្រើប្រាស់យន្តការដែលមានស្រាប់ឈ្មោះថា ក្រុមការងារផ្នែកអប់រំតាមវិស័យ ដើម្បីប្រមូល ធាតុចូល ពីបណ្តាអ្នកពាក់ព័ន្ធនានាដើម្បីរៀបចំធ្វើផែនការថវិកា។

៤.១.២ គ្រឹះស្ថានអប់រំឯកជនបានចូលរួមចែកសម្ភារៈដល់ បុគ្គលិក និងអាហារូបករណ៍ដល់អ្នកដែលខ្វះខាតដោយផ្តល់ទាំងអាហារ និងការស្នាក់នៅដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍។

៤.១.៣. ក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតយន្តការច្រើនក្នុងការបង្រៀន និងរៀន ដល់គ្រូ និងសិស្សដោយផ្អែកតាមតំបន់ និងលទ្ធភាពរបស់សិស្សក្នុងមូលដ្ឋានជាក់ស្តែង។

៤.១.៤ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ និងគោលនយោបាយផ្សេងៗទៀតដែលផ្តោតលើការបង្កើនគុណភាពអប់រំ។ ក្នុងនោះក្រសួងក៏បានប្តេជ្ញាក្នុងការវិភាជលើចំណាយថវិកាសាធារណៈក្នុងកម្រិត២០ភាគរយ។

៤.១.៥ ក្រសួងអប់រំយុវជន និងកីឡា មានក្រុមការងារចម្រុះ ដែលមានសមាសភាពមកពីថ្នាក់ក្រសួង អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ដែលធ្វើការលើវិស័យអប់រំ ។ វេទិកានេះមិនត្រឹមតែផ្តោតលើការរៀបចំថវិកាទេតែថែមទាំងជាក្រុមការងារមួយដែលតែងតែឆ្លុះបញ្ចាំងពីការអនុវត្តការងារផងដែរ។

**៤.២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមកនៃការវិនិយោគលើការអប់រំនិងកុមារ(៦ចំណុច)៖**

៤.២.១ ក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ១៩ ការសិក្សារបស់កុមារ មិនបានជិតដល់ជាពិសេសគឺកុមារនៅតាមជនបទ ដោយសារតែពួកគេខ្វះមធ្យោបាយ សម្ភារៈ ក្នុងការចូលរៀនតាមប្រព័ន្ធអនឡាញ។ លើសពីនេះទៀតកុមារភាគច្រើនមិនបានរៀនគ្រប់គ្រាន់ដោយសារតែជីវភាពកុមារ និងខ្លះត្រូវធ្វើចំណាកស្រុកតាមឪពុកម្តាយ។

៤.២.២ ការយល់ដឹងពីបច្ចេកទេសបង្រៀន និងរៀនតាមប្រព័ន្ធអនឡាញនៅមានកម្រិតនៅឡើយទាំងលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

៤.២.៣ ការចូលរួមពីវិស័យឯកជនក្នុងការលើកកម្ពស់វិស័យឯកជនក្នុងបរិបទកូវីដ១៩កំពុងជួបបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរដោយសារមិនមានលទ្ធភាពបង់ថ្លៃអាគារសិក្សា។ សាលារៀនឯកជនខ្លះ ត្រូវបង្កើនគ្រូបង្រៀន និងទិញសម្ភារសម្រាប់បង្រៀនអនឡាញ។

៤.២.៤ ដោយសារការទទួលបានការអប់រំមិនស្មើគ្នាក្នុងបរិបទកូវីដ១៩ សមត្ថភាពសិស្សក្នុងការបន្តឆ្នាំសិក្សាអាចនឹងមានកម្រិតផ្សេងគ្នាហើយក៏នឹងធ្វើឱ្យប៉ះពាល់ដល់កម្រិតដែលសិស្សមួយចំនួនអាចនឹងបោះបង់ការសិក្សាផងដែរ។

៤.២.៥ កុមារដែលមានពិការភាពមិនមានលទ្ធភាពក្នុងការចូលរៀន ក្នុងបរិបទកូវីដ ១៩

៤.២.៦ ការយល់ដឹងរបស់អាណាព្យាបាលក្នុងការតាមដានការសិក្សារបស់កូននៅមានកម្រិតនៅឡើយ។ ក្នុងបរិបទនេះកុមារមួយចំនួនបានឆក់យកឱកាសក្នុងការរៀនអនឡាញដោយពួកគេមិនបានផ្តោតលើកម្មវិធីសិក្សាហើយ បានប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យា ដែលមិនល្អ ដូចជាការលេងហ្គេមជាដើម។

**៤.៣. សំណូមពរ និងអនុសាសន៍លើទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនៃការវិនិយោគ លើការអប់រំ និងកុមារ(៨ចំណុច)៖**

៤.៣.១ ស្នើឱ្យមានការអប់រំផ្នែកផ្លូវចិត្តដល់ប្រជាពលរដ្ឋទៅទៅ និងសិស្សានុសិស្សក្នុងអំឡុងពេល និងក្រោយពេលនៃការរាតត្បាតនៃជំងឺកូវីដ ១៩។

៤.៣.២ ស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡាជួយបន្ថែមទៀតក្នុងការបង្រៀនបំប៉នដល់កុមារ និងសិស្សានុសិស្សក្រោយពេលជំងឺកូវីដ១៩ បញ្ចប់ និង គួរតែសិក្សាលើចំនុចខ្វះខាតជាក់ស្តែង ដែលកើតមាននៅតាមមូលដ្ឋាន។

៤.៣.៣ ស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នផ្សេងៗទៀត ជួយគិតពីសុខុមាលភាពរបស់សិស្សនិងគ្រូក្នុងបរិបទកូវីត១៩ ជាពិសេសបញ្ហាផ្លូវចិត្ត។

៤.៣.៤ ស្នើឱ្យក្រសួងអប់រំជួយពង្រឹងនូវវិធីសាស្ត្របង្រៀនដល់លោកគ្រូ អ្នកគ្រូ និងចាត់ចែងលោកគ្រូអ្នកគ្រូទៅបង្រៀនទៅតាមឯកទេសរបស់ខ្លួន។

៤.៣.៥ ស្នើឱ្យគ្រឹះស្ថានអប់រំផ្តោតលើគុណភាពឱ្យបានច្រើនជាងបរិមាណដែលបានបញ្ចប់ និងគួរមានការតម្រង់ទិសដល់កុមារ និងសិស្សានុសិស្សបន្ថែមទៀតដើម្បីឱ្យពួកគេកាន់តែមានមនសិការជាតិ។ ក្រសួងគួរមានការលើកទឹកចិត្ត ឱ្យនិស្សិតផ្តោតការសិក្សា ទៅលើមុខជំនាញ របស់ខ្លួនឱ្យ បានច្បាស់លាស់ ជាជាងចាប់យកពហុជំនាញប៉ុន្តែពុំមានគុណភាព។

៤.៣.៦ ស្នើឱ្យសាលារៀន អាជ្ញាធរមូលដ្ឋាន និងអាណាព្យាបាលរបស់សិស្សធ្វើការជាមួយគ្នាដើម្បីតាមដានត្រួតពិនិត្យការសិក្សារបស់កុមារ។

៤.៣.៧ ស្នើឱ្យក្រសួងអប់រំ បញ្ចូលវិស័យឯកជនដែលធ្វើការលើវិស័យអប់រំបានចូលរួមជាមួយក្រុមការងារបច្ចេកទេសចម្រុះរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងកិច្ចប្រជុំនានា។

៤.៣.៨ បញ្ចូលកម្មវិធីអប់រំសម្រាប់កុមារដែលមានតម្រូវការអប់រំពិសេសនៅតាមសាលារៀនរដ្ឋ និងឯកជន បង្កើតឱ្យមានអ្នកប្រឹក្សាយោបល់ និងមគ្គុទេសអាជីពតាមសាលា ដើម្បីឱ្យសិស្សទទួលបានការតម្រង់ទិស និងជ្រើសរើសមុខវិជ្ជាតាមទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់ខ្លួន។

**៥.១. ចំណុចវិជ្ជមាននៃយន្តការដែលមានស្រាប់ និងការអនុវត្តកន្លងមកនៃការចូលរួមរបស់សាធារណជនក្នុងដំណើរការកសាងផែនការរៀបចំថវិកា និងការត្រួតពិនិត្យ តាមដានការអនុវត្តផែនការថវិកានៅថ្នាក់ក្រោមជាតិ(៥ចំណុច)៖**

៥.១.១ មានការបណ្តុះបណ្តាលដល់អាជ្ញាធរនៅថ្នាក់ក្រោមជាតិលើយន្តការ និងដំណើរការនៃការរៀបចំផែនការដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ផងដែរ។មានកែសម្រួលខ្លះនិងសម្រាយពីដំណើរការក្នុងការស្នើសុំថវិកាឃុំសង្កាត់ប្រចាំឆ្នាំ និងបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដើម្បីយល់ពីដំណើរការក្នុងការស្នើសុំ។

៥.១.២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកែសម្រួលលើវិធីសាស្រ្តបង់ពន្ធតាមរយៈការបង្កើតកម្មវិធីឌីជីថលដើម្បីបង្កើនភាពងាយស្រួលក្នុងការបង់ពន្ធ។ ព័ត៌មានស្តីពីពន្ធដាបានផ្សព្វផ្សាយនៅលើគេហទំព័រ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៥.១.៣ រដ្ឋាភិបាលបានប្រមូលពន្ធលើសផែនការ ដោយសារតែមានការកែទម្រង់ហិរញ្ញវត្ថុសាធារណៈបានល្អ។

៥.១.៤ រដ្ឋបាល ក្រុងស្រុក ខណ្ឌមានផែនការ៥ឆ្នាំ និងតែងតែបានធ្វើ ផែនការវិនិយោគ៣ឆ្នាំរំកិលជារៀងរាល់ឆ្នាំដោយបានបើកឱកាសឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតផងដែរ។

៥.១.៥ មានច្បាប់គតិយុត្តិ និងសារាចរណ៍ណែនាំ ពីរបៀបនៃការអនុវត្តការរៀបចំផែនការថវិកានៅកម្រិតថ្នាក់ក្រោមជាតិដែលលក្ខណៈល្អប្រសើរ។

**៥.២. បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការអនុវត្តកន្លងមកនៃការចូលរួមរបស់សាធារណជនក្នុងដំណើរការកសាងផែនការរៀបចំថវិកា និងការត្រួតពិនិត្យ តាមដានការអនុវត្តផែនការថវិកានៅថ្នាក់ក្រោមជាតិ(៦ចំណុច)៖**

៥.២.១ បើទោះបីជាយើងមានយន្តការលើកកម្ពស់ឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក៏ដោយតែការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតក្នុងការរៀបចំថវិកាឃុំសង្កាត់។

៥.២.២ សមត្ថភាពរបស់មន្រ្តីឃុំសង្កាត់នៅមានកម្រិត ដែលពិបាកក្នុងការផ្ទេរចំណេះដឹងដល់ប្រជាពលរដ្ឋលើការរៀបចំថវិកាឃុំសង្កាត់។

៥.២.៣ មានការបើកចំហរឱ្យមានការរចូលរួមរបស់ពលរដ្ឋ និងលើកជាសំណើផងដែរ តែទោះជាយ៉ាងណាក៏ដោយគណៈកម្មការសហគមន៍បានចូលរួមក្នុងការដាក់សំណើថវិកាក្នុងការទ្រទ្រង់លើវិស័យព្រៃឈើ តែមិនមានថវិកាក្នុងការគាំទ្រនោះទេ។

៥.២.៤ ការផ្សព្វផ្សាយជូនដំណឹងពីការរៀបចំថវិកាឃុំ មិនទាន់បានទូលំទូលាយនៅឡើយ។

៥.២.៥ ប្រជាពលរដ្ឋមិនសូវបានចូលរួម ដោយសារតែគាត់មិនសូវបានបញ្ចេញយោបល់ ឬការរៀបចំនៅឆ្ងាយពីផ្ទះរបស់គាត់។

៥.២.៦ ការអភិវឌ្ឍនៅមូលដ្ឋានភាគច្រើនផ្តោតលើផ្នែករូបវន្ត ច្រើនជាងអរូបវន្តដែលធ្វើឱ្យបញ្ហាដែលជាតម្រូវការអាទិភាពសម្រាប់ប្រជាពលរដ្ឋដែលងាយរងគ្រោះមិនសូវបានឆ្លើយតប។

**៥.៣. សំណូមពរ និងអនុសាសន៍លើទិសដៅជាអាទិភាពដែលត្រូវអនុវត្តបន្តដោយភាគីពាក់ព័ន្ធនៃការចូលរួមរបស់សាធារណជន ក្នុងដំណើរការកសាងផែនការរៀប ចំថវិកា និងការត្រួតពិនិត្យ តាមដានការអនុវត្តផែនការថវិកានៅថ្នាក់ក្រោមជាតិ(៨ចំណុច)៖**

៥.៣.១ ស្នើឱ្យក្រុមប្រឹក្សាឃុំសង្កាត់លើក ផែនការអភិវឌ្ឍន៍៥ឆ្នាំឱ្យបានច្បាស់ហើយធានាបាននូវការចូលរួមផ្តល់យោបល់ពីប្រជាពលរដ្ឋប្រកបដោយ គណនេយ្យ និងតម្លាភាព។ ការរៀបចំផែនការវិនិយោគឃុំសង្កាត់ត្រូវផ្តល់អាទិភាពខ្លះក្នុងការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍ជាពិសេសគឺផ្តល់ថវិកាទ្រទ្រទ្រង់សហគមន៍ព្រៃឈើ។

៥.៣.២ ស្នើឱ្យបណ្តុះបណ្តាលបន្ថែមទៀតដល់ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតលើរបៀបនៃការរៀបចំថវិកានៅថ្នាក់ក្រោមជាតិ។

៥.៣.៣ ស្នើឱ្យអាជ្ញាធរមានការផ្សព្វផ្សាយដល់ឱ្យបានទូលំទូលាយពលរដ្ឋពីថវិកាដែលនឹងអនុវត្តនៅក្នុងឃុំសង្កាត់របស់ខ្លួននីមួយៗ។

៥.៣.៤ ស្នើឱ្យអនុវត្តច្បាប់គតិយុត្តិ សារាចរណ៍ណែនាំ ដោយធានាបានថាប្រជាពលរដ្ឋមានការយល់ដឹងដោយធ្វើការរួមគ្នាជាមួយអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា។

៥.៣.៥ ស្នើឱ្យរាជរដ្ឋាភិបាលបន្តតម្លើងថវិកាបន្ថែមទៀតដល់ថ្នាក់ក្រោមជាតិយ៉ាងហោចណាស់ក្នុងកម្រិត ១០% នៃថវិកាជាតិ។

៥.៣.៦ ស្នើឱ្យមានការពង្រឹងការបង្ខឹកបន្ថែមពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ និងជួយជំរុញបន្ថែមដល់ថ្នាក់មូលដ្ឋានក្នុងការលើកកម្ពស់ឱ្យមានការចូលរួមពេញលេញពីប្រជាពលរដ្ឋ។

៥.៣.៧ ស្នើឱ្យមានការផ្សព្វផ្សាយបន្ថែមតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមស្តីពីការប្រកាសព័ត៌មានរបស់ឃុំសង្កាត់។

៥.៣.៨ ស្នើឱ្យមានយន្តការផ្សារភ្ជាប់រវាងក្រសួងមហាផ្ទៃ និង ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកទឹកចិត្តឱ្យយុវជននៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យចូលរួមក្នុងការអភិវឌ្ឍជាមួយឃុំសង្កាត់។

ជាចុងបញ្ចប់ យើងទាំងអស់គ្នាដែលជាអ្នកចូលរួមនៅក្នុងវេទិកានេះ សូមសម្តែងនូវការប្តេជ្ញាចិត្ត បន្តធ្វើការរួមគ្នាក្នុងភាពជាដៃគូប្រកបដោយវិជ្ជាជីវៈ និងប្រកបដោយបរិយាកាសអំណោយផលដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការរៀបចំថវិកា និងការត្រួតពិនិត្យតាមដាន ជាពិសេសនៅថ្នាក់ក្រោមជាតិ។